# ទិវាយុវជនអន្តរជាតិឆ្នាំ២០២៣

# វេទិកាយុវជនកម្ពុជា

### ក្រោមប្រធានបទ៖

## «លំហសេរីភាពរបស់យុវជន ឆ្ពោះទៅរកយុត្តិធម៌សង្គមល្អប្រសើរ»

## សេចក្តីថ្លែងការណ៍រួម ស្តីពី លទ្ធផលនៃកិច្ចពិគ្រោះយោបល់ លើបញ្ហាប្រឈម ក្តីកង្វល់ និងអនុសាសន៍របស់យុវជន

## នាឱកាសប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ២០២៣ និងវេទិកាយុវជនកម្ពុជា ក្រោមមូលបទ

## "លំហសេរីភាពយុវជន ឆ្ពោះទៅរកយុត្តិធម៌សង្គមល្អប្រសើរ"

*រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣*

កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ សមាគម និងអង្គការសង្គមស៊ីវិលចំនួន ៨ស្ថាប័នបានសហការរៀបចំការប្រារព្ធទិវាយុវជនអន្តរជាតិឆ្នាំ២០២៣ និងវេទិកាយុវជនកម្ពុជា ក្រោមមូលបទ "**លំហសេរីភាពយុវជន ឆ្ពោះទៅរកយុត្តិធម៌សង្គមល្អប្រសើរ**" ក្នុងបរិយាកាសល្អប្រសើរ ជាមួយនឹងវត្តមានអ្នកចូលរួមចំនួន ២៨០នាក់ ក្នុងនោះស្ត្រីចំនួន ១៣៦នាក់។

ការប្រារព្ធ និងរៀបចំកម្មវិធីដ៏មានសារៈសំខាន់សម្រាប់យុវជនកម្ពុជានេះ បានរៀបចំឡើងដោយមានកិច្ចពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញ សិស្ស-និស្សិត ព្រះសង្ឃ យុវជនអ្នកការពារព្រៃឈើ តំណាងយុវជនមកពីសហគមន៍មូលដ្ឋាន យុវជនជនជាតិដើមភាគតិច ក្រុមយុវជនសហគ្រិនវ័យក្មេង យុវជនក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងយុវជនមកពីមជ្ឈដ្ឋានចម្រុះផ្សេងៗទៀត ក្នុងសិក្ខាសាលាចំនួន៤ រួមមាន ១).ការគោរពសិទ្ធិមនុស្ស និងសេរីភាពបញ្ចេញមតិ ២).ការលើកកម្ពស់ការចូលរួមកិច្ចការពារយុត្តិធម៌ និងធនធានធម្មជាតិ ៣).ការអប់រំ និងសីលធម៌សង្គម និង ៤).ភាពសកម្មនិយមលើឌីជីថលដើម្បីចូលរួមកែលម្អសង្គម។

កិច្ចពិគ្រោះយោបល់លើប្រធានបទទាំងនោះបានកំណត់ឃើញបញ្ហាប្រឈមសម្រាប់យុវជន ដែលត្រូវចូលរួមដោះស្រាយពីគ្រប់ភាគី និងផ្តល់ជាអនុសាសន៍ដូចមានបង្ហាញតាមប្រធានបទនីមួយៗខាងក្រោម៖

## ១. ការគោរពសិទ្ធិមនុស្ស និងសេរីភាពបញ្ចេញមតិ

រដ្ឋធម្មនុញ្ញកម្ពុជាបានផ្តល់សិទ្ធិយ៉ាងពេញលេញឱ្យប្រជាពលរដ្ឋចូលរួមយ៉ាងពេញលេញក្នុងកិច្ចការពលរដ្ឋ នយោបាយ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ខណៈគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ក៏បានលើកកម្ពស់ការចូលរួមរបស់យុវជនលើគ្រប់វិស័យផងដែរ។ ការដាក់ចេញបម្រាមមិនឱ្យមានការជជែកពីបញ្ហានយោបាយនៅក្នុងគ្រឹះស្ថានសិក្សាគ្រប់កម្រិត ការបិទអាជ្ញាប័ណ្ណផ្សព្វផ្សាយរបស់សារព័ត៌មានឯករាជ្យ និងការរាំងខ្ទប់មិនឱ្យចូលទៅអានព័ត៌មានពីគេហទំព័រមួយចំនួននៅដើមឆ្នាំ២០២៣ បានធ្វើឱ្យយុវជនបាត់បង់ឱកាសឈ្វេងយល់ និងពិភាក្សាអំពីបញ្ហានយោបាយ និងសង្គម។ លើសពីនេះ ការចាប់ខ្លួនសកម្មជនសង្គម និងពលរដ្ឋដែលសកម្មជាមួយនឹងគណបក្សនយោបាយជំទាស់ បានកើតមានឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៩ បានក្លាយជាកត្តារាំងដល់ភាពសកម្មនិយមនៃការចូលរួមរបស់យុវជននៅក្នុងដំណើការប្រជាធិបតេយ្យ។ កត្តាជាច្រើនផ្សេងទៀត ក៏ត្រូវបានក្លាយជាបញ្ហាប្រឈម និងក្តីកង្វល់របស់ក្រុមយុវជនរួមមាន ការរឹតត្បិតចំពោះការចូលរួមសកម្មភាពសង្គម ការតម្រូវឱ្យក្រុមយុវជនដែលធ្វើសកម្មភាពស្ម័គ្រចិត្តស្នើសុំច្បាប់ពីអាជ្ញាធរមុននឹងធ្វើសកម្មភាពសហគមន៍ ការទាមទារឱ្យសមាគម និងអង្គការមហាជនជូនដំណឹងមុនធ្វើសកម្មភាពដែលផ្ទុយទាំងស្រុងពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាដើម។ ដោយបន្តមើលឃើញបញ្ហាជាច្រើននៅបន្តជះឥទ្ធិពលយ៉ាងអវិជ្ជមានដល់ការអនុវត្តសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ-អន្តរជាតិ ដែលចាំបាច់ត្រូវស្វែងរកដំណោះស្រាយសម្រាប់ផ្តល់លំហឡើងវិញ ចំពោះការចូលរួមរបស់យុវជន ទើបក្រុមយុវជនដែលបានចូលរួមទិវាយុវជនអន្តរជាតិឆ្នាំ២០២៣ និងវេទិកាយុវជនកម្ពុជា បានផ្តល់***អនុសាសន៍***ដល់ភាគីពាក់ព័ន្ធដូចខាងក្រោមៈ

១. ប្រទេសកម្ពុជា គួរពន្លឿនការអនុម័តឱ្យប្រើប្រាស់ច្បាប់ស្តីពីការទទួលបានព័ត៌មាន ឱ្យបានឆាប់រហ័សដើម្បីបង្កលក្ខណៈងាយស្រួលដល់ការទទួលលំហព័ត៌មាន និងការចូលរួមប្រកបដោយគុណភាពទាំងការផ្តល់សំណើរ និងយោបល់ទៅដល់អ្នកមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងការចូលរួមបានឱ្យពេញលេញ។

២.រាជរដ្ឋាភិបាល និងក្រសួងព័ត៌មាន ពិនិត្យឡើងវិញក្នុងការស្វែងរកលទ្ធភាពសម្រាប់ការបើកដំណើរការផ្សព្វផ្សាយវិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី )និងបង្កលក្ខណៈងាយស្រួលក្នុងការចូលទៅស្វែងរកព័ត៌មានពីប្រភពចម្រុះ ដើម្បីឱ្យយុវជនអាចទទួលបានព័ត៌មានទូលំទូលាយ។

៣. ក្រសួងអប់រំ យុវជន និងកីឡា ត្រូវលុបចោលបម្រាមការពិភាក្សាពីបញ្ហាសង្គម និងនយោបាយ នៅក្នុងគ្រឹះស្ថានអប់រំសាធារណៈគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡា ក៏គួរពិចារណាដាក់បញ្ចូលមេរៀនអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចូលទៅក្នុងកម្មវិធីសិក្សារដ្ឋផងដែរ។

## ២. ការលើកកម្ពស់ការចូលរួមកិច្ចការពារយុត្តិធម៌ និងធនធានធម្មជាតិ

ការរឹតត្បិតការចូលរួមរបស់សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច និងក្រុមយុវជន មិនឱ្យចូលរួមល្បាតនៅក្នុងតំបន់ការពារធម្មជាតិចំនួនពីរ គឺ ដែនជម្រកសត្វព្រៃព្រៃឡង់ និងដែនជម្រកសត្វព្រៃព្រះរការ គឺ

ជាការរំលោភលើសិទ្ធិពលរដ្ឋ និងសហគមន៍មូលដ្ឋានយ៉ាងធ្ងន់ធ្ងរ ដែលឱ្យពួកគេបាត់បង់ឱកាសចូលរួមកិច្ចការពារធនធានធម្មជាតិ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ ការឃាត់ខ្លួន និងចាប់ខ្លួនសកម្មជនបរិស្ថានដាក់ពន្ធនាគារ ធ្វើឱ្យក្រុមយុវជនមានការព្រួយបារម្ភក្នុងការចូលរួម និងសុវត្ថិភាពរបស់ពួកគេ។ ការកាត់ ការកែសម្រួល ការជួល និងការផ្តល់ដីតំបន់ការពារធម្មជាតិ ព្រមទាំងតំបន់សក្តានុពលបម្រើប្រយោជន៍សាធារណៈ (បឹងធម្មជាតិ ឆ្នេរ ភ្នំ ស្ទឹង សមុទ្រ ជាដើម) ទៅឱ្យក្រុមហ៊ុនឯកជនអភិវឌ្ឍន៍ ដោយពុំមានការពិគ្រោះយោបល់ពីសហគមន៍មូលដ្ឋាន បានធ្វើឱ្យពួកគេបាត់បង់ផលប្រយោជន៍ពីការអាស្រ័យផល ការទទួលបានបរិស្ថានស្អាត និងប៉ះពាល់ដល់ជីវៈចម្រុះ។ បន្ថែមពីនេះ មានបញ្ហាមួយចំនួនទៀតដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន ធនធានធម្មជាតិ និងជីវៈចម្រុះរបស់កម្ពុជា ហើយកម្ពុជាត្រូវដោះស្រាយរួមមាន ការមិនគួរបន្តអនុញ្ញាតឱ្យក្រុមហ៊ុនអង្គរ ផ្លាយវូត ខុំអែលធីឌី នាំចេញឈើ មិនត្រូវអនុញ្ញាតឱ្យមានការនាំចេញរ៉ែមិនទាន់បានកែច្នៃ ការកាប់ទន្រ្ទានយកដីព្រៃដោយខុសច្បាប់ ការបន្តបទល្មើសនេសាទនិងធនធានធម្មជាតិ ការប្រមាញ់និងជួញដូរសត្វព្រៃដោយខុសច្បាប់ជាដើម។ ដោយមើលឃើញកត្តារឹតត្បិតសិទ្ធិចូលរួមការពារបរិស្ថាន និងការព្រួយបារម្ភពីចីរភាពនៃធនធានធម្មជាតិនៅកម្ពុជា ក្រុមយុវជនដែលបានចូលរួមទិវាយុវជនអន្តរជាតិឆ្នាំ២០២៣ និងវេទិកាយុវជនកម្ពុជា បានផ្តល់***អនុសាសន៍***ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

៤. រាជរដ្ឋាភិបាល បង្កើនការបើកចំហ ផ្តល់ឱកាស លើកទឹកចិត្ត ដល់យុវជន សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិចឱ្យចូលរួមក្នុងកិច្ចការពារបរិស្ថាន ធនធានធម្មជាតិ និងព្រៃឈើឱ្យបានទូលំទូលាយ។ ជាមួយគ្នានេះ គួរតែបញ្ឈប់ការចោទប្រកាន់ ការឃុំខ្លួន និងរឹតត្បិតលំហចូលរួមរបស់យុវជនក្នុងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ឱ្យបានទូលំទូលាយ។

៥. រាជរដ្ឋាភិបាល គួរបញ្ឈប់ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនឯកជន ធ្វើការលុបបឹង លុបឆ្នេរ លុបទន្លេ កាយយករ៉ែ កាយយកថ្មភ្នំ ការនាំឈើចេញទៅក្រៅប្រទេស និងលើកកម្ពស់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិកម្ពុជាឱ្យមានចីរភាព។

៦. គណៈកម្មការជាតិរៀបចំសហគមន៍អេកូទេសចរណ៍ និងក្រសួងបរិស្ថាន គួរបង្កើនការផ្តល់ការគាំទ្រទាំងបច្ចេកទេស ធនធាន ស្មារតី ថវិកា ដល់សហគមន៍ព្រៃឈើ សហគមន៍តំបន់ការការពារធម្មជាតិ ក្រុមយុវជន ដែលមានឆន្ទៈចូលរួមកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ។ ចំពោះការរៀបចំប្រព័ន្ធអេកូទេសចរណ៍ ក្រសួងមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋាន គួរធ្វើការគាំទ្រដល់សកម្មភាពសហគមន៍មូលដ្ឋានក្នុងការរៀបចំសហគមន៍អេកូទេសចរណ៍ ដោយមានការគាំទ្រពីក្រុមហ៊ុនជំនាញណាមួយ តែពុំមែនជាការមកវិនិយោគដោយផ្ទាល់ឡើយ។

## ៣. ការអប់រំ និងសីលធម៌សង្គម

កត្តាកង្វះគ្រឹះស្ថានសិក្សាសាធារណៈនៅតាមតំបន់ដាច់ស្រយាល និងអន្តេវាសិកដ្ឋាន បានធ្វើឱ្យនិស្សិតក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាលបាត់បង់ឱកាសក្នុងការទទួលបានការអប់រំល្អប្រសើរ។ ការមិនបើកទូលាយឱ្យមានកិច្ចពិភាក្សាអំពីបញ្ហានយោបាយ សង្គម និងការចូលរួមជាមួយនឹងអង្គការមហាជនឯករាជ្យបានក្លាយជាកត្តាព្រួយបារម្ភចំពោះការកសាងសមត្ថភាពយុវជន។ ការផ្សព្វផ្សាយរូបភាពអាសអាភាស ការផ្សព្វផ្សាយពាក្យសម្តី និងកាយវិការមិនសមរម្យ និងការផ្សព្វផ្សាយរូបភាពអសីលធម៌នៅលើបណ្តាញសង្គម បានបង្កផលរំខានយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរនិងសីលធម៌ដ៏ល្អរបស់សង្គមកម្ពុជា។ ដើម្បីជំរុញការដោះស្រាយបញ្ហាប្រឈម សម្រាប់ការឈានទៅរកការកសាងប្រព័ន្ធអប់រំ និងសីលធម៌សង្គមមានភាពល្អប្រសើរ ក្រុមយុវជនដែលបានចូលរួមទិវាយុវជនអន្តរជាតិឆ្នាំ២០២៣ និងវេទិកាយុវជនកម្ពុជា បានផ្តល់***អនុសាសន៍*** ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

៧. រាជរដ្ឋាភិបាល បង្កើនលទ្ធភាពផ្តល់អាហាររូបករណ៍ និងកសាងអន្តេវាសិកដ្ឋានទាំងនៅតាមបណ្តាខេត្តនាតំបន់ដាច់ស្រយាល និងរាជធានីភ្នំពេញ ដើម្បីបង្កើតឱកាស និងបង្កភាពងាយស្រួលដល់យុវជនឱ្យទទួលបានការអប់រំបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ការកសាងហេដ្ឋារចនាសម្ព័ន្ធអប់រំ និងគុណភាពអប់រំ គួរត្រូវបានពង្រីកទៅកាន់តំបន់សហគមន៍ដាច់ស្រយាលផងដែរ។

៨. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើនការយកចិត្តទុកដាក់ត្រួតពិនិត្យមាតិកា និងអ្នកផលិត និងការផ្សព្វផ្សាយមាតិកាបែបអាសអាភាស និងការផ្សព្វផ្សាយរូបភាពអសីលធម៌នៅលើបណ្តាញផ្សព្វផ្សាយសង្គម។

## ៤. ភាពសកម្មនិយមលើឌីជីថលដើម្បីចូលរួមកែលម្អសង្គម

ប្រព័ន្ធផ្សព្វផ្សាយសង្គម ត្រូវបានក្លាយជាវិធីសាស្ត្រថ្មីមួយដែលត្រូវបានប្រើប្រាស់សម្រាប់ជាការអប់រំ ការកំសាន្ត ការប្រាស្រ័យទាក់ទង និងការបញ្ចេញមតិយោបល់។ ការបញ្ចេញមតិយោបល់របស់ក្រុមយុវជនត្រូវបានកត់សម្គាល់ថានៅមានការរឹតត្បិត និងព្រួយបារម្ភ ដោយសារមានករណីសម្តែងមតិនៅតាមបណ្តាញសង្គម ត្រូវបានអាជ្ញាធរកោះហៅមកសួរនាំ និងប្រើប្រាស់ជាភ័ស្តុតាងសម្រាប់ការដាក់បន្ទុកតាមផ្លូវតុលាការជាដើម។ ក្រុមហ៊ុន និងកន្លែងធ្វើការងារមួយចំនួន នៅមិនទាន់មានគោលនយោបាយការពារការបៀតបៀន និងគោលការណ៍សុវត្ថិភាពសម្រាប់ការប្រើប្រាស់ឌីជីថល ដែលបានបង្កឱ្យមានការបៀតបៀន ការរើសអើង ការរំលោភលើឯកជនភាពនៃអ្នកប្រើប្រាស់ និងការលួចទិន្នន័យជាដើម។ ការបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ និងល្បែងភ្នាល់លើអនឡាញ សុទ្ធតែបង្កផលរំខានយ៉ាងខ្លាំងដល់សុវត្ថិភាពអ្នកប្រើប្រាស់បណ្តាញសង្គមនៅកម្ពុជា ជាពិសេសប្រជាជនវ័យក្មេង។ ភាគច្រើននៃក្តីបារម្ភ ចំពោះការប្រើប្រាស់បណ្តាញសង្គម គឺបណ្តាលមកពីការការប្រើប្រាស់បណ្តាញសង្គមឌីជីថលដោយពុំមានក្រមសីលធម៌ និងកង្វះចំណេះដឹងអំពីគោលការណ៍សុវត្ថិភាពឌីជីថល។ ដើម្បីជំរុញការដោះស្រាយ

បញ្ហាប្រឈម និងក្តីកង្វល់ជុំវិញការប្រើប្រាស់បណ្តាញសង្គម និងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្រុមយុវជនដែលបានចូលរួមទិវាយុវជនអន្តរជាតិឆ្នាំ២០២៣ និងវេទិកាយុវជនកម្ពុជា បានផ្តល់***<u>អនុសាសន៍</u>***ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

៩. រាជរដ្ឋាភិបាលត្រូវធានា និងជំរុញឱ្យវិស័យឯកជនបង្កើតគោលនយោបាយប្រឆាំងការបៀតបៀនកេរ្តិ៍ខ្មាស ព្រមទាំងបង្កើតឱ្យមានការិយាល័យទទួលពាក្យបណ្តឹងអំពីការបៀតបៀន ការបោកបញ្ឆោត និងការកេងប្រវ័ញ្ចតាមប្រព័ន្ធឌីជីល។ ការជំរុញឱ្យជនរងគ្រោះមានភាពងាយស្រួលក្នុងការរាយការណ៍ និងដាក់ពាក្យបណ្តឹងទៅកាន់អង្គភាពជំនាញ ឬដាក់ពាក្យប្តឹងទៅអាជ្ញាធរពាក់ព័ន្ធដើម្បីដំណោះស្រាយឆាប់រហ័ស និងទាន់ពេលវេលា។

១០. ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបើកវគ្គបណ្តុះបណ្តាលដល់សិស្សានុសិស្សចាប់ពីបឋមសិក្សាឡើងទៅ ដើម្បីមានចំណេះដឹងពីសុវត្ថិភាព សីលធម៌នៃការប្រើប្រាស់បណ្តាញសង្គម និងសន្តិសុខឌីជីថល ដើម្បីឱ្យពលរដ្ឋអាចទទួលបានការអប់រំល្អប្រសើរអំពីប្រព័ន្ធបច្ចេកវិទ្យាជាមូលដ្ឋាន។

បញ្ហាប្រឈមពាក់ព័ន្ធបរិយាសសង្គម នយោបាយ ការគោរពសិទ្ធិមនុស្ស សីលធម៌សង្គម និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យព័ត៌មានវិទ្យាឌីជីថល នៅតែជាកត្តាជះឥទ្ធិពលយ៉ាងខ្លាំងដល់យុវជនកម្ពុជាទាំងឥរិយាបថ ផ្នត់គំនិត ផ្លូវចិត្ត និងសុវត្ថិភាព ដែលបានក្លាយជាកត្តារាំងស្ទះដល់ភាពសកម្មនៃការចូលរួមសកម្មភាពសង្គម នយោបាយ និងការសម្រេចចិត្តចំពោះជោគវាសនារបស់ពួកគេ។ ខណៈប្រទេសកម្ពុជា ជាប្រទេសដែលមានយុវជន និងប្រជាជនវ័យក្មេងចំនួនភាគច្រើនធៀបនឹងប្រជាជនសរុប យើងទាំងអស់គ្នាសង្ឃឹមថា អនុសាសន៍ទាំង១០ចំណុចខាងលើនឹងត្រូវរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធទទួលយកពិចារណា ដើម្បីឆ្លើយតបទៅនឹងសេចក្តីកង្វល់ និងបញ្ហាប្រឈម ដែលពួកយើងបានលើកឡើងនាឱកាសប្រារព្ធទិវាយុវជនអន្តរជាតិ និងវេទិកាយុវជនកម្ពុជា ឆ្នាំ២០២៣នេះ។

ចំពោះមុខប្រទេសកម្ពុជា ជាប្រទេសដែលមានយុវជន និងប្រជាជនវ័យក្មេងភាគច្រើន រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ គួរបង្កលក្ខណៈ និងលក្ខខណ្ឌល្អប្រសើរដល់យុវជន ឱ្យបានចូលរួមយ៉ាងសកម្មភាពទាំងកិច្ចការសង្គម នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការអនុវត្តសិទ្ធិពលរដ្ឋឱ្យបានពេញលេញ ទើបពួកគេមានកាលានុវត្តភាព និងនាវានុវត្តគ្រប់គ្រាន់ ក្នុងការចូលរួមសកម្មភាពសង្គមជាតិបានល្អប្រសើរ។ ការបើកលំហសេរីភាពពេញលេញសម្រាប់យុវជន គឺធ្វើឱ្យពួកគេឆ្ពោះទៅរកការចូលរួមមួយដែលមានភាពសកម្ម ដើម្បីជំរុញវឌ្ឍនភាព និងបង្កើតបានភាពល្អប្រសើរនៃយុត្តិធម៌សង្គម។ ផ្ទុយទៅវិញ ប្រសិនបើយុវជន ពុំទទួលបានលំហសេរីភាពពេញលេញ និងបរិយាកាសសង្គមមិនល្អប្រសើរនោះយុវជននឹងក្លាយជាកម្លាំងចលករបំពេញមហិច្ឆតារបស់អ្នកនយោបាយតែប៉ុណ្ណោះ ហើយសំឡេងរបស់ពួកគេនឹងនៅតែត្រូវបានបំបាត់ចោល។

ដូចបានរៀបរាប់អំពីបញ្ហាប្រឈម ក្តីកង្វល់ និងអនុសាសន៍ខាងលើ យើងខ្ញុំទាំងអស់គ្នាដែលជាសមាគម អង្គការសង្គមស៊ីវិល និងក្រុមយុវជន មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថារាជរដ្ឋាភិបាលថ្មី ដែលមានសមាសភាពជាគណៈរដ្ឋមន្ត្រីភាគច្រើនវ័យក្មេង និងស្ថាប័នពាក់ព័ន្ធ នឹងយកចិត្តទុកដាក់ក្នុងការទទួលយក និងដោះស្រាយឱ្យមានប្រសិទ្ធភាពជាទីបំផុត សម្រាប់លើកទឹកចិត្តដល់ការចូលរួមរបស់យុវជនឱ្យអស់ពីសក្តានុពល និងថាមពលក្នុងភាពជាពលរដ្ឋសកម្មសម្រាប់ប្រទេសកម្ពុជារបស់យើងទាំងអស់គ្នា។


***ព័ត៌មានបន្ថែមសូមទាក់ទង៖***

**លោក ហេខ គឹមហុខ** ប្រធានផ្នែកកម្មវិធីស្រាវជ្រាវ និងតស៊ូមតិនៃសមាគមបណ្តាញយុវជនកម្ពុជា
តាមរយៈលេខទូរស័ព្ទ 0967888368 / 092667599

**កញ្ញា ប៉ាញ ចិន្តា** អនុប្រធានបរិស្ថាននៃអង្គការ ជេស្វីតសឺវីសកម្ពុជា
តាមរយៈលេខទូរស័ព្ទ 015 585 214

**លោក ភើត សារ៉ាយ** ប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ
តាមរយៈលេខទូរស័ព្ទ 096 242 4393